# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

កម្មវិធីរបស់ The Asian International Justice Initiative

ឆ្នាំទី១ លេខ ១៦ សប្តាហ៍ទី១៦ (១០-១២ សីហា ឆ្នាំ ២០០៩)


## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : លោក កាំង ហ្គិចអ៊ាវ ហៅ ឌុច (អតីតប្រធានមន្ទីរ ស-២១)*

## ១. សេចក្តីផ្តើម

*"មនុស្សគ្រប់រូបទទួលការឈឺចាប់យ៉ាងធំធេង ឥឡូវដល់វេលាព្យាបាលរបួសហើយ..."*[1] ។

ក្នុងកំឡុងពេលបីថ្ងៃសាវនាការ នាសប្តាហ៍នេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីសរុបចំនួន ១២រូប ។ សាក្សី ៣រូប ផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ និង ៩រូបទៀត ជាការអានកំណត់ហេតុស្តាប់ចម្លើយ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងអាន កំណត់ហេតុស្តាប់ចម្លើយសាក្សី (ឬសេចក្តីសង្ខេបនៃសេចក្តីថ្លែងការណ៍) បន្តបង្ហាញពីភាពពន្លឿននីតិវិធីទាំងមូល ។ ការបារម្ភមួយ លើកឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងការអានសេចក្តីថ្លែងការណ៍សាក្សី គឺជនជាប់ចោទលះបង់សិទ្ធិខ្លួន ក្នុងការកោះហៅសាក្សីក្នុងកាលៈទេសៈជាក់លាក់ ដែលមានចែងនៅវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ។ អង្គជំនុំជម្រះបានទុកបញ្ហា នេះមួយឡែក ដោយយល់ថា ជនជាប់ចោទបានលះបង់សិទ្ធិជំទាស់នៅកិច្ចប្រជុំរៀបចំសវនាការលើកមុន ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្មរបស់សាក្សី

សក្ខីកម្មសាក្សីខាងក្រោមនេះ ត្រូវបានស្តាប់ នាសប្តាហ៍នេះ :

**សក្ខីកម្មដោយផ្ទាល់មាត់ :**

- លោក **ឈុន ផល** អតីតឆ្មាំយាមគុក នៅមន្ទីរ ស-២១

---

[1] សំដីអ្នកស្រី **ប៊ូ ថុន** នៅពេលសួរដេញដោលដោយលោកចៅក្រម Lavergne នៅថ្ងៃពុធ ទី១២ សីហា ២០០៩ ។

- លោក **សោម ម៉េត** អតីតឆ្មាំយាមគុកពិសេស នៅមន្ទីរ ស-២១
- អ្នកស្រី **ប៊ូ ថុន** សមាជិក *"ប្រជាជនថ្មី"* ដែលត្រូវបញ្ជូនទៅព្រៃស ។

**សក្ខីកម្មដោយការអានកំណត់ហេតុស្តាប់ចម្លើយ :**

- លោក **ម៉ក់ ស៊ីធីម** អតីតពេទ្យ នៅមន្ទីរ ស-២១
- លោក **តយ តេង** អតីតឆ្មាំយាមគុក ប្រចាំការបរិវេណខាងក្រោមមន្ទីរ ស-២១
- លោក **សោម សំអុល** អតីតនិរសារ នៅក្រសួងការបរទេស
- លោក **ជ័យ សុភារ៉ា** អនុប្រធានអគ្គនាយកដ្ឋានសារមន្ទីរទួលស្លែង
- លោក **មាស ប៉េងត្រី** អតីតអ្នកបើកបររថយន្ត នៅមន្ទីរ ស-២១ ដែលដឹកជញ្ជូនអ្នកទោសទៅមន្ទីរប្រល័យពូជសាសន៍ជើងឯក
- លោក **អ៊ុក ប៊ុនសេង** អតីតទាហ៊ានខ្មែរក្រហម ត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២៤
- លោក **អ៊ាម ប៉ាន** អតីតឆ្មាំគុក នៅមន្ទីរ ស-២១
- អ្នកស្រី **ថាច់ សៀក** អតីតទាហ៊ានខ្មែរក្រហម ត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២៤
- អ្នកស្រី **កាំង ប៉ាន់** អតីតបុគ្គលិកស្ត្រីនៅមន្ទីរ ស-២១ ត្រូវបញ្ជូនទៅមន្ទីរ ស-២៤ ។

***វិសាលភាពទទួលខុសត្រូវរបស់ឌុច*** : នាសប្តាហ៍នេះ ទិដ្ឋភាពភស្តុតាងសំខាន់ៗបានបដិសេធនឹងការលើកឡើងជាច្រើនលើករបស់ **ឌុច** ដែលថា *គាត់គ្មានជម្រើសក្រៅពីការអនុវត្តន៍តាមបញ្ជាថ្នាក់លើ* ។

***ការសួរចម្លើយធ្វើឡើងដោយឌុច :*** **ឌុច** នៅតែរក្សាជំហរដ៏រឹងមាំថា គាត់មិនដែលសួរចម្លើយអ្នកទោសដោយផ្ទាល់ទេ លើកលែងតែមនុស្សម្នាក់គត់ ។ ទោះជាយ៉ាងណា លោក **សោម ម៉េត** បានរៀបរាប់ចំពោះមុខអង្គជំនុំជម្រះនូវហេតុការណ៍កើតឡើងពីរដងដោយថៃ្ងដន្យថា លើកទី១ : នៅពេលគាត់ឃើញ **ឌុច** នៅគុកពិសេស **ឌុច** បានចូលរួមដោយផ្ទាល់សួរចម្លើយអ្នកទោស និងធ្វើទារុណកម្មអ្នក ទោស ដោយវាយនឹងរំពាត់ផ្តៅ ។ លើកទី២ : នៅពេលលោក **សោម ម៉េត** ត្រូវបានបញ្ជាឱ្យយាមអ្នកទោសដែលថ្នាក់លើទើបធ្វើទារុណកម្មរួច គាត់បានឃើញ **ឌុច** កាន់រំពាត់ផ្តៅ និងឈរជាមួយអ្នកយាមក្បែរនោះ ។

***ឥទ្ធិពល និងគោលជំហរថ្នាក់លើ :*** លោក **សោម សំអុល** ជាអតីតនិរសារក្រសួងការបរទេសអះអាងថា គាត់បានជួប **ឌុច** នៅកន្លែងធ្វើការរបស់គាត់ ដែលជាកន្លែង **ឌុច** ទៅចូលរួមប្រជុំប្រចាំសប្តាហ៍ជាមួយថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា រួមមាន **ប៉ុល ពត. សុន សេន. តា ម៉ុក. នួន ជា** និង **អៀង សារី** ។ ការចូលរួមប្រជុំប្រចាំសប្តាហ៍ **ឌុច** បានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៧ រហូត ឆ្នាំ១៩៧៩ ។ លោក **សោម សំអុល** សន្និដ្ឋានថា **ឌុច** បានយកចម្លើយសារភាពអ្នកទោសជូនថ្នាក់លើរៀងរាល់កិច្ចប្រជុំ ។ សាក្សីបន្តថា គាត់បានឃើញថ្នាក់លើចូលរួមពិធីរៀបអាពាហ៍ពិពាហ៍ **ឌុច** រួមមាន **សុន សេន. នួន ជា.** និង **អៀង ធីរិទ្ធ. . .** នេះដោយសារភាពជិតស្និទ្ធរវាង **ឌុច** នឹងថ្នាក់លើ ។

***ដែនមេត្តាធម៌នៅមន្ទីរ ស-២១?*** ការរៀបរាប់ពីឱកាសត្រាប្រណីនៅមន្ទីរ ស-២១ ទោះបីជួបហានិភ័យនៃការដាក់ទណ្ឌកម្មពី **ឌុច** ។ លោក **សោម ម៉េត** បានរំលឹកពីវិធីដែលគាត់ការពារអ្នកយាមម្នាក់ភ្លេចក្រមានៅបន្ទប់ឃុំឃាំង ក្រោយមកអ្នកទោសយកប្រើចង កធ្វើអត្តឃាដខ្លួនឯង ប៉ុន្តែលោក **សោម ម៉េត** បានបង្អាក់ការនេះ ហើយលាក់ជាសម្ងាត់ ។ ជាងនេះទៀត គាត់ជឿជាក់ថា គាត់ត្រូវបញ្ជូនទៅព្រៃស ដោយសារ **ហ៊ឹម ហ៊ុយ** បុគ្គលិកជាន់ខ្ពស់មន្ទីរ ស-២១ បានជួយការពារបញ្ចៀសពីការកំទេច នៅពេលថ្នាក់លើដឹងថា បងប្រុសរបស់ **សោម ម៉េត** ត្រូវចាប់ និងចាត់ទុកជាខ្មាំង ។

***ការឆ្លើយតបរបស់ឌុច :*** **ឌុច** បានបដិសេធដាច់អហង្ការចំពោះសក្ខីកម្មសាក្សីទាក់ទងនឹងការចូលរួមសួរចម្លើយរបស់គាត់ និងវត្តមាន *"ថ្នាក់ដឹកនាំជាន់ខ្ពស់"* ចូលរួមពិធីអាពាហ៍ពិពាហ៍គាត់ ។ គាត់បានថ្លែងថា គាត់មិនដែលដើរពិនិត្យមើល **ទុយ** សួរចម្លើយទេ ដោយសារគាត់ស្គាល់ពីឧបនិស្ស័យរបស់ **ទុយ** គឺប្រើហឹង្សា ដូច្នេះគាត់ព្យាយាមដកខ្លួនចេញឆ្ងាយពីបញ្ហានេះ លើកលែងមួយករណី ។ គាត់បានបញ្ជាក់ឯកសារមួយដែលបង្ហាញជាក់លាក់ថា គាត់មិនបានទៅមើលការសួរចម្លើយធ្វើឡើងដោយ **ទុយ** ទេ ព្រមទាំងថ្លែងថា ទោះបីជាគាត់ចង់ធ្វើដូច្នេះក៏មិនមានពេលចូលរួមសួរចម្លើយអ្នកទោសដែរ ក្នុងគាត់នាមជាប្រធានមន្ទីរ ស-២១ នោះ ។

***ការចាប់ខ្លួនដោយជាប់ពាក់ព័ន្ធខ្មាំង :*** អ្នកទោសទាំងអស់ ទោះនៅមន្ទីរ ស-២១ ឬគុកព្រៃស ឬជើងឯក ត្រូវចាប់ខ្លួនដោយគ្រាន់តែកំហុសជាប់ពាក់ពន្ធ័មនុស្សដែលអង្គការចាត់ទុកថាជាជនក្បត់ ។ ***ឧទា*** : លោកស្រី **ប៊ូ ថុន** សន្និត់ថា ប្តីរបស់គាត់ **ភោគ ហ៊ន** ត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ ដោយសារជាខ្សែបណ្តាញរបស់ **កុយ ធួន** ជាមនុស្សត្រូវចាប់ខ្លួនពីបទក្បត់ជាតិ ។ **ឌុច** បានបញ្ជាក់លើការសន្និត់នេះថា ការចាប់ខ្លួន និងការសម្លាប់លោក **ភោគ ហ៊ន** គឺជាគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការបោសសម្អាត *"ខ្សែខ្មាំង"* ។ ករណីលោក **ថាច់ សៀក** ត្រូវបានបញ្ជូនទៅគុកព្រៃស ដោយសារតួនាទីជាសមាជិកនៅភូមិភាគឧត្តរ ។ ជំងឺសង្ស័យបានកើតមានទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ជាក់ស្តែង លោក **ថាច់ សៀក** ត្រូវគេប្រាប់ថា មិនត្រឹមតែរូបគាត់នៅភូមិភាគឧត្តរម្នាក់ទេ ដែលជាជនក្បត់ សូម្បីម្តាយឪពុកក៏ចាត់ជាជនក្បត់ដែរ ។

## មន្ទីរ ស-២១ :

***គុកពិសេស :*** ក្នុងនាមជាអតីតអ្នកយាមគុកពិសេសនៅមន្ទីរ ស-២១ លោក **សោម ម៉េត** បានបំភ្លឺពីមុខងារទីកន្លែងនោះ ។ គុកពិសេសត្រូវប្រើជាពិសេសសម្រាប់ឃុំកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ ។ លក្ខខណ្ឌឃុំឃាំងនៅគុកនេះ មិនខុសពីបន្ទប់ឃុំឃាំងរួមនៅមន្ទីរ ស-២១ ទេ ទោះជាមានផ្នែកសំខាន់ខ្លះៗក៏ដោយ ដូចជាអ្នកជាប់ឃុំឃាំងនៅគុកពិសេសទទួលការមុជទឹកសម្អាតខ្លួន មិនមែនដោយការបាញ់ទឹកទេ ។ បន្ថែមលើនេះ អ្នកទោសទទួលបានឆ្នាំងសម្រាប់បន្ទោបង់លាមក មិនមែនកេះគ្រាប់ដូចអ្នកទោសធម្មតាទេ ។

***ស្ថានភាពឃុំឃាំង :*** ដូចកាលសប្តាហ៍មុន ភស្តុតាងអំពីស្ថានភាពឃុំឃាំងនៅមន្ទីរ ស-២១ បានបង្ហាញកាន់តែច្បាស់ដោយសាក្សីនាសប្តាហ៍នេះ ។ ចំណុចខុសគ្នាត្រូវបានលើកឡើង នៅពេលលោក **ជុំ ផល** រៀបរាប់ពីការមុជទឹក ដែលអ្នកទោសមុជដោយខ្លួន

ឯង មិនមែនដោយការបាញ់ទឹកដាក់ទេ (ខុសពីសក្ខីកម្មមុនៗ អ្នកទោសត្រូវអ្នកយាមបាញ់ទឹកដាក់) ។ ភស្តុតាងមុន ដែលលើកពីគោលបំណងព្យាបាលអ្នកទោសនៅមន្ទីរ ស-២១ គឺទុកសម្រាប់បញ្ចប់ចម្លើយសារភាពប៉ុណ្ណោះ និងបញ្ជាក់បន្ថែមដោយសក្ខីកម្មលោក **ម៉ក់ ស៊ីធីម** ។ គាត់លើកឡើងថា អ្នកសួរចម្លើយបានណែនាំគាត់យ៉ាងជាក់លាក់ឱ្យព្យាបាលតាមវិធីនោះ ចំពោះអ្នកទោសមិនទាន់បញ្ចប់ចម្លើយសារភាព ។ ទន្ទឹមនឹងនោះ គាត់ទទួលស្គាល់ថា ឱសថប្រើប្រាស់នៅមន្ទីរ ស-២១ ជាទូទៅមិនមានប្រសិទ្ធិភាពទេ ។

***ការធ្វើទារុណកម្ម និងការសួរចម្លើយ :*** សាក្សីដែលជាអតីតអ្នកយាមមន្ទីរ ស-២១ បានរៀបរាប់ថា ពួកគាត់បានឃើញស្នាមវាយនិងរបួសលើខ្លួនអ្នកទោសទើបសួរចម្លើយចប់ ។ សក្ខីកម្មនេះហាក់បង្ហាញពីការប្រើប្រាស់វិធីធ្វើទារុណកម្មមួយចំនួន ដូចជា ការដកក្រចក ឆក់ខ្សែភ្លើង វាយដំបង... ។ ចំពោះលោក **សោម ម៉េត** បានថ្លែងថា គាត់បានឃើញការធ្វើទារុណកម្មលើអ្នកទោសដោយផ្ទាល់ ដោយការវាយនឹងដំបងឬស្សី ការឆក់ខ្សែភ្លើងលើប្រដាប់ភេទ និងទងត្រចៀក ព្រមទាំងការដកក្រចក យកម្ជុលចាក់ក្រចក និងច្រកក្បាលក្នុងស្បោងផ្លាស្ទិច ។

***ការបូមឈាម :*** អតីតពេទ្យមន្ទីរ ស-២១ លោក **ម៉ក ស៊ីធីម** បានអះអាងថា គាត់មិនដែលបានឃើញការបូមឈាមដោយផ្ទាល់ទេ ហើយក៏មិនដឹងពីកន្លែងបូមឈាមដែរ ប៉ុន្តែគាត់លើកឡើងថា គាត់ធ្លាប់ព្យាបាលអ្នកទោសប្រមាណជា ២០-៣០នាក់ ដែលត្រូវគេបូមឈាម ។ គាត់បានឃើញផ្លោកឈាមខូចត្រូវគេបោះចោលជិតកន្លែងស្នាក់នៅរបស់គាត់ ។ **ឌុច** បានបញ្ជាក់ថា ឈាមទាំងនោះត្រូវរក្សាទុកនៅមន្ទីរពេទ្យ៩៨ ដែលជាមន្ទីរពេទ្យតែមួយរបស់មន្ទីរ ស-២១ ។ ជនជាប់ចោទរំលឹកថា ការបូបឈាមអនុវត្តតាំងពី **ណាត** គ្រប់គ្រងមន្ទីរ ស-២១ ហើយបន្តបូមជាញឹកញាប់នៅពេលគាត់កាន់តំណែង ។

***ការសម្រិតសម្រាំង :*** លោក **សោម ម៉េត** កត់សម្គាល់ថា គាត់កាន់តែខ្លាច **ឌុច** ខ្លាំងឡើងៗ នៅពេលគាត់ដឹងថា អ្នកយាមគុកពិសេសបាត់ខ្លួន ។ ដំបូងអង្គភាពមានសមាជិកប្រមាណជា ៤០-៥០នាក់ ក្រោយមកសល់តែ ៤-៥នាក់ ប៉ុណ្ណោះ និងបន្តបាត់ខ្លួនជាបណ្តើរៗ ។ លោក **សោម ម៉េត** ឆ្លើយពីអារម្មណ៍គាត់ នៅពេលឃើញអ្នកយាមត្រូវកំទេចថា *"មិនខុសអ្វីពីសត្វគោក្របី ប្រើហើយត្រូវគេសម្លាប់ចោលទេ"* ។

***គុកព្រៃស :*** ការរៀបរាប់ភាគច្រើនរបស់សាក្សី អំពីគុកព្រៃស គឺមានភាពប្រហាក់ប្រហែលគ្នា ។ យោងតាមលោកស្រី **ប៊ូ ថុន** គុកព្រៃសជាកន្លែងទុកអ្នកទោសជាបណ្តោះអាសន្ន មុនបញ្ជូនទៅអង្គភាព ឬទីកន្លែងផ្សេង ។ លោកស្រី **ថាច់ សៀក** បានរៀបរាប់ថា គុកព្រៃសជាទីកន្លែងដាក់អ្នកទោសក្បត់សមយ័មុន ក្នុងគោលបំណងលត់ដំ និងកែប្រែឡើងវិញ។

***គុកឥតជញ្ជាំង :*** គុកព្រៃសគ្មានរបងហ៊ុំព័ទ្ធ អ្នកជាប់ឃុំមិនជាប់ខ្នោះនៅផ្ទះ និងគ្មានអ្នកយាមកាម ប៉ុន្តែ លោក **តយ តេង** លោក **កាំង ប៉ាន់** និងលោកស្រី **ប៊ូ ថុន** បានរៀបរាប់ថា គ្មានអ្នកណាហ៊ានរត់ ឬដើរហើរដោយសេរីទេ ព្រោះជា *"គុកឥតជញ្ជាំង"* ។

***សមាសភាពអ្នកជាប់ឃុំ :*** លោកស្រី **ថាច់ សៀក** រៀបរាប់ថា ចំនួនអ្នកជាប់ឃុំនៅគុកព្រៃសមានប្រមាណជា ២០០០នាក់ ។ យោងតាមលោកស្រី **ថាច់ សៀក** លោក **តយ តេង** អ្នកស្រី **ប៊ូ ថុន** និងលោក **កាំង ប៉ាន់** លើកឡើងថា អ្នកជាប់ឃុំនៅគុកព្រៃសរួមមាន ប្រជាជនថ្មី ទាហានមកពីភូមិភាគបូពា ឧត្តរ បញ្ញាវន្ត ប្រជាជនជាប់ពាក់ពន្ធ័បញ្ហាសីលធម៌ និងពួកប្រឆាំង ។ លោក **កាំង ប៉ាន់** បានលាតត្រដាងពីការឃុំខ្លួនកុមារអាយុពី ៨-១០ឆ្នាំ មកជាមួយឪពុកម្តាយ ដែលត្រូវចោទប្រកាន់ ថាជាប់និន្នាការ ។ កុមារខ្លះជាកូនមន្ត្រីជាន់ខ្ពស់សម័យមុន ។

***ការប្រព្រឹត្តចំពោះអ្នកទោស :*** ដូចបានលើកឡើងក្នុងសក្ខីកម្មមុនៗ ការធ្វើការនៅគុកព្រៃស គឺតឹងតែង និងមានពេលសម្រាកតិចតួចបំផុត លើកលែងតែលោក **តយ តេង** បានថ្លែងថា គាត់មិនត្រូវចាត់ឱ្យយាមយប់ដើម្បីការពារកុំឱ្យអ្នកទោសរត់ទេ ។ យោងតាមលោកស្រី **ថាច់ សៀក** ការព្យាបាលមិនគ្រប់គ្រាន់ទេ អ្នកទោសទទួលបានថ្នាំតែ ២-៣គ្រាប់ នៅពេលពួកគេឈឺ ។ លោក **តយ តេយ** លោកស្រី **ប៊ូ ថុន** និងលោកស្រី **ថាច់ សៀក** រៀបរាប់ថា អ្នកទោសទទួលបានអាហារ ២ដង ក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាច ជាបបររាវ ប៉ុន្តែក៏មានករណីលើកលែង ពេលខ្លះអ្នកទោសទទួលបានអាហារ ៣ពេល ក្នុងមួយថ្ងៃ ។ លោកស្រី **ប៊ូ ថុន** បន្ថែមថា ទិន្នផល ស្រូវ ពោត សណ្តែក និងបន្លែ ទទួលផលច្រើន ប៉ុន្តែអ្នកជាប់ឃុំនៅតែទទួលរបបអាហារមិនគ្រប់គ្រាន់ ។

***ការមកដល់ និងយកអ្នកទោសចេញពីមន្ទីរ ស-២៤ :*** គ្រប់សាក្សីពាក់ព័ន្ធបានព្រមព្រៀងជាឯកច្ឆ័នថា អ្នកទោសដែលមិនយកទៅលត់ដំ ត្រូវបញ្ជូនទៅមន្ទីរ ស-២១ ដើម្បីសម្លាប់ ។ សាក្សី **កាង ប៉ាន់** លើកឡើងថា ឡានដឹកអ្នកទោសនាពេលយប់ទៅមន្ទីរ ស-២៤ ដូចគ្នានឹងឡានដឹកគាត់ទៅវគ្គរៀនសូត្រនៅមន្ទីរ ស-២១ ។ យោងតាម **ថាច់ សៀក** គាត់បានឮសម្លេងឡានដឹកជញ្ជូនមនុស្សជារៀងរាល់យប់ ។ សាក្សី **ប៉ូ ថន់** លើកឡើងថា គាត់បានឃើញគេដឹកកុមារ ២-៣ឡាន និងអ្នកទោសត្រូវបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ ស្ថានភាពភ័យខ្លាចចំពោះអ្នកទោសដែលអាចត្រឡប់មកវិញ ពួកគេមិនហ៊ាននិយាយស្តីអ្វីសោះ ។

***មន្ទីរប្រល័យពូជសាសន៍ជើងឯក :*** តាមការបញ្ជាក់ពីសក្ខីកម្មមុនៗ លោក **តយ តេង** និង **មាស ប៉េងគ្រី** បានឱ្យដឹងថា អ្នកទោសយកទៅជើងឯក ដំបូងដាក់នៅផ្ទះឈើមួយ មុននឹងយកសម្លាប់ ។ យោងតាម **តយ តេង** ការសម្លាប់នៅជើងឯកមានតែជនជាតិខ្មែរ ហើយមិនមានសូម្បីតែក្មេងៗ តាមសក្ខីកម្មលោក **មាស ប៉េងគ្រី** ។ ទោះជាយ៉ាងណា លោក **ប៉ូ ថន់** បានឱ្យដឹងថា គាត់ធ្លាប់ឃើញសាកសពកុមារ ពេលគាត់ទៅជើងឯកនៅឆ្នាំ១៩៧៩ ។ បន្ថែមលើនេះ លោក **តយ តេង** បានបញ្ជាក់លម្អិតពីវិធីសម្លាប់អ្នកទោស ដោយការវាយនឹងកញ្ចឹងក មុននឹងអារក ឬវះពោះ ។ គាត់មិនឮសម្រែកអ្វីទេ ក្រៅពីសម្លេងខ្យល់បក់នាពេលនោះ ។

***សេចក្តីសង្កេតរបស់ឌុច :*** នៅថ្ងៃពុធ **ឌុច** បានប្រកាសថា គាត់នឹង *"ទទួលយកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដោយមិនមានការតវ៉ា"* ។ ការនេះបង្ហាញពីចេតនារបស់ជនជាប់ចោទនឹងមិនប្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោសរបស់អង្គជំនុំជម្រះ ។ បន្ថែមលើនោះ **ឌុច** បានបង្ហាញមន្ទិលសង្ស័យពីភាពពិតនៃសក្ខីកម្មរបស់សាក្សី **ម៉ក់ ស៊ីធីម** លោក **មាស ប៉េងគ្រី** លោក **អ៊ុក ប៊ុនសេង** និងលោក **អ៊ាម ហ៊ាន** ។

***លទ្ធផលបន្សល់ទុកដល់អ្នករស់រានមានជីវិត :*** លោកស្រី **ប៉ូ ថន់** លើកឡើងដោយរំជួលចិត្តបង្ហាញពីជីវិតរស់នៅដោយគ្មានអ្នកជាទីស្រឡាញ់ និងជីវិតពោរពេញដោយការបាត់បង់ នាសប្តាហ៍នេះ ។ ការនេះរំលឹកថា ទោះជាសម័យកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ ក៏នៅបន្សល់ការ *"ឈឺចាប់"* របស់ជនរងគ្រោះដែលរស់រានមានជីវិត ។ លោកស្រីនៅតែដក់ជាប់ក្នុងចិត្តនូវទិដ្ឋភាពកូន និងប្តីគាត់ជានិច្ច ដោយលើកដំបូងន្ទានមួយថា *"មនុស្សគ្រប់រូបទទួលរងឈឺចាប់យ៉ាងធំធេង ឥឡូវដល់វេលាព្យាបាលរបួសហើយ"* ។

## ២. អំណះអំណាង និងកង្វល់ក្នុងសវនាការ

***ជនជាប់ចោទលះបង់សិទ្ធិកោះហៅសាក្សីមកបញ្ជាក់តាមវិធាន ៨៤(១) :*** បន្ទាប់ពីស្តាប់សក្ខីកម្មសាក្សី **តយ តេង** នៅថ្ងៃអង្គារ សហព្រះរាជអាជ្ញាអន្តរជាតិលោក **Anees Ahmed** បានស្នើថា មេធាវីការពារក្តីថ្លែងមិនជំទាស់ពីរបាយការណ៍សាក្សី **តយ តេង** ដូច្នេះមិនចាំបាច់កោះហៅចំពោះមុខអង្គជំនុំជម្រះទេ ។ សំណើនេះចែងក្នុងវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង បញ្ហាដែលជនជាប់ចោទមិនមានឱកាសក្នុងការថ្លែងទៅសក្ខីកម្មសាក្សី **តយ តេង** កំឡុងពេលអង្គបុរេជំនុំជម្រះ ។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញពីការធានាថា មេធាវីការពារក្តីនឹងមិនលើកពីសិទ្ធិតាមមាត្រា ៨៤(១) ជំទាស់នាពេលអនាគតលើសក្ខីកម្មសាក្សីរូបនេះ ។

ជាការឆ្លើយតប អង្គជំនុំជម្រះបានប្រកាសលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា មិនចាំបាច់ ។ ការនេះបង្ហាញឱ្យឃើញថា ការលះបង់សិទ្ធិរបស់មេធាវីការពារក្តីតាមវិធាន ៨៤(១) ត្រូវបានអនុវត្ត ដោយសារមេធាវីការពារក្តីបានលះបង់សិទ្ធិទាមទារមុនកិច្ចប្រជុំរៀបចំសវនាការ ។ ការសម្រេចរបស់អង្គជំនុំជម្រះសំខាន់ត្រង់ថា បានបញ្ជាក់នៅពេលមេធាវីការពារក្តីអាចពិចារណាពីការលះបង់សិទ្ធិខ្លួនតាមមាត្រា ៨៤(១) ។

## ៣. ការចូលរួម និង ការការពារសាក្សី និងជនរងគ្រោះ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** វត្តមានដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃច័ន្ទ មានចំនួន ១៤រូប ថ្ងៃអង្គារ និងថ្ងៃពុធ ចំនួន ១២រូប ។

***ដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យស្នើសុំចំពោះមុខអង្គជំនុំជម្រះ :*** យោងតាមរបៀបវារៈថ្មីរបស់តុលាការ បានបញ្ចូលពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាឯកសារភស្តុតាង ។ ថ្មីៗនេះ ដើមបណ្តឹង ១៤រូប ក្នុងចំណោម ៩៣រូប ត្រូវកំណត់ឱ្យបង្ហាញខ្លួនចំពោះមុខអង្គសវនាការក្នុងការសួរដេញដោលនៅ ២សប្តាហ៍ខាងមុខ ក៏ប៉ុន្តែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ លោកស្រី **Fabienne Trusse Naprous** បានបញ្ជាក់ថា នៅថ្ងៃពុធ ក្រុមលោកស្រីនឹងដកសំណើសុំបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី **E2-81** ក្នុងការសួរដេញដោល ដោយសារមិនអាចរកបានឯកសារគាំទ្រ ។

បន្ថែមលើនោះ ពាក្យស្នើសុំដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦រូប ស្ថិតក្រោមការពិចារណាក្នុងការដាក់ចំពោះមុខអង្គជំនុំជម្រះ ។ មេធាវីការពារក្តីនឹងត្រូវផ្តល់ឱកាសឱ្យជំទាស់លើសំណើសុំទាំងនោះនៅថ្ងៃច័ន្ទ *(១៧ សីហា ២០០៩)* ។ គួរកត់សម្គាល់បញ្ហាសំខាន់ៗពាក់ព័ន្ធពាក្យស្នើសុំដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានលើកឡើងកំឡុងកិច្ចដំណើរការនីតិវិធី នាសប្តាហ៍នេះ ទោះបីជា

ត្រូវលើកទៅធ្វើការតវ៉ានាសប្តាហ៍បន្ទាប់ ។ ការឆ្លើយតបរបស់អង្គជំនុំជម្រះលើករណីនេះ គប្បីរំលឹកដល់ភាគីដែលមានបញ្ហាចង់លើកឡើង អាចធ្វើនៅកាលបរិច្ឆេទលើកក្រោយ ។

***មេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ឯកសារបន្ថែមគាំទ្រពាក្យស្នើសុំកូនក្តីខ្លួន :*** ពេញមួយសប្តាហ៍នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូនអង្គជំនុំជម្រះ និងភាគីនូវឯកសារបន្ថែម ដើម្បីគាំទ្រពាក្យស្នើសុំកូនក្តីខ្លួន ។ ភាពបន្ទាន់បង្ខំជាក់ស្តែងមួយ គឺដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់ឯកសារបន្ថែមដល់មេធាវីការពារក្តីនៅសប្តាហ៍នេះ ដើម្បីងាយស្រួលជំទាស់លើពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ឬសក្ខីកម្មកូនក្តីខ្លួន នៅពេលកោះហៅចំពោះមុខអង្គជំនុំជម្រះ ។ កិច្ចប្រឹងប្រែងនេះ ធ្វើឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកាត់បន្ថយមន្ទិលសង្ស័យ ដែលបង្កើតក្តីកង្វល់មុននេះ ។

***វត្តមានមេធាវីប្រឹក្សាយោបល់សាក្សី :*** លោកមេធាវី **គង់ សំអុន** បន្តវត្តមានក្នុងកិច្ចនីតិវិធី ក្នុងនាមជាមេធាវីប្រឹក្សាយោបល់សាក្សីនៅមន្ទីរ ស-២១ ។ វត្តមានលោកត្រូវប្រគល់ជូននៅថ្ងៃពុធ ខណៈសាក្សីជនរងគ្រោះសួរដេញដោលចំពោះមុខអង្គជំនុំជម្រះ ។

***តំណាងរួមក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី :*** វិធីមុននៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលក្រុមមេធាវីនីមួយៗដាក់ការសន្និដ្ឋាន និងតាំងសំណួររៀងៗខ្លួន ជាលទ្ធផលបង្កឱ្យមានសំណួរច្រំដែល និងប្រាសចាកពីប្រធានបទ ដែលធ្វើឱ្យកិច្ចដំណើរការនីតិវិធីមានភាពរយឺតយ៉ាវ ។ ការប្រឈមនឹងម៉ោងពេលកំណត់ ដែលរឹតបន្តឹងដោយអង្គជំនុំជម្រះលើការសួរដេញដោលនោះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានប្រឹងប្រែង និងព្រមព្រៀងសហការគ្នា ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាពខ្ពស់ចំពោះការសួរដេញដោលនៅថ្ងៃអង្គារ និងថ្ងៃពុធ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមបានតែងតាំងមេធាវីម្នាក់ជាតំណាងក្នុងការសួរដេញដោលសាក្សី ។ ក្រុមអ្នកឃ្លាំមើលតុលាការយល់ថា ការអនុវត្តន៍នៃជម្រើសជ្រើសតាំងតំណាងរួមបង្កើតបានជាការរឹតចំណងយ៉ាងស្អិតរមួត និងកាត់បន្ថយការកើតឡើងសំណួរច្រំដែល ។

***ភាពឈឺចាប់ចេញពីសេចក្តីសង្កេតរបស់ជនជាប់ចោទ :*** ទោះបីមានសេចក្តីសម្រេចមុនរបស់អង្គជំនុំជម្រះ ណែនាំឱ្យជនជាប់ចោទធ្វើសេចក្តីសង្កេតខ្លួនចំពោះមុខអង្គជំនុំជម្រះក៏ដោយ **ឌុច** នៅតែថ្លែងដោយផ្ទាល់ចំពោះភាគីដើមបណ្តឹងរដ្ឋប្បវេណី **ប៊ូ ថុន** ។ ជាលទ្ធផល សាក្សីមានអារម្មណ៍រំជួលចិត្តកើនឡើងកាន់តែខ្លាំង បណ្តាលឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ លោកស្រី **Silke Studinsky** ធ្វើការជំទាស់លើករណីនេះ ។ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានរំលឹកដល់ **ឌុច** មិនឱ្យធ្វើសេចក្តីសង្កេតណា ដែលនាំឱ្យសាក្សីនឹកឃើញពីការឈឺចាប់របស់ខ្លួនឡើង ប៉ុន្តែបានបដិសេធនឹងការជំទាស់របស់លោកស្រី **Silke** ដោយផ្អែកលើមូលដ្ឋានថា ជនជាប់ចោទមានសិទ្ធិធ្វើសេចក្តីសង្កេតខ្លួន ។ សិទ្ធិបញ្ចេញយោបល់របស់ជនជាប់ចោទនៅតែបន្ត ដោយមិនគិតពីសុខមាលភាពសាក្សី ។ ក្រុមអ្នកឃ្លាំមើលតុលាការសូមស្នើថា នៅពេលសាក្សីមានអារម្មណ៍រំជើបរំជួលកំឡុងពេលជនជាប់ចោទធ្វើសេចក្តីសង្កេត គម្បីសាក្សីមានជម្រើសអាចចាកចេញពីបន្ទប់សាវនាការបាន ។

## ៤. ការគ្រប់គ្រងដំណើរការសវនាការ

### ការគ្រប់គ្រងផ្នែកតុលាការ

***កាលវិភាគ :*** អង្គជំនុំជម្រះបានប្រកាសថា ពីរសប្តាហ៍បន្តបន្ទាប់នឹងស្តាប់សេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណី របៀបវារៈនេះគួរត្រូវចាប់ផ្តើមនាសប្តាហ៍នេះ យោងតាមដីកាស្តីពីការរៀបចំកាលវិភាគសវនាការចេញកាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ ។ គួររំលឹកថា ដំណើរការនីតិវិធីនាបច្ចុប្បន្នមានការយឺតយ៉ាវ ៣ថ្ងៃ យោងតាមកាលវិភាគគ្រោងទុក ។ នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះបានរៀបចំរបៀបវារៈថ្មីចាំបាច់សម្រាប់សប្តាហ៍នេះ ។ ជាទូទៅ កិច្ចនីតិវិធីមិនស្របតាមដំណើរការរបៀបវារៈទេ ។

***ការគ្រប់គ្រងពេលវេលា :*** ជាក់ស្តែងមានការកង្វល់ថា ដំណើរការសវនាការនាសប្តាហ៍នេះបានបញ្ចប់តាមកាលវិភាគកំណត់ ដោយសារថា អង្គជំនុំជម្រះមិនចំណាយពេលខ្ជះខ្ជាយ និងខិតខំពន្លឿនកិច្ចដំណើរការក្តី ។ ដូចការសួរដេញដោលលោក **សោម ម៉ែត** បានបញ្ចប់មុនកាលវិភាគកំណត់នៅថ្ងៃអង្គារ អង្គជំនុំជម្រះបង្គាប់ឱ្យអានកំណត់ហេតុស្តាប់ចម្លើយសាក្សី ២រូប បន្ថែមលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ៥រូប ដែលបានគ្រោងទុក ។

***វត្តមានភាគីនានា :*** លោក **តាន់ សេណារ៉ុង** តំណាងសហព្រះរាជអាជ្ញាជាតិ ពេញមួយសប្តាហ៍ និងសហព្រះអាជ្ញាអន្តរជាតិតំណាងដោយលោក **Anees Ahmed** នៅថ្ងៃច័ន្ទ និងព្រឹកថ្ងៃអង្គារ ហើយជំនួសដោយលោក **Vincent De Wilde** ចាប់ពីរសៀលថ្ងៃអង្គារតទៅ ។ សហមេធាវីការពារក្តីអន្តរជាតិលោក **Francois Roux** អវត្តមាននាសប្តាហ៍នេះ ប៉ុន្តែជំនួសដោយលោកស្រី **Canizares** ។

***វត្តមានសាធារណជន :*** កិច្ចដំណើរការនីតិវិធីមានប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះករពេញមួយសប្តាហ៍ ដោយសារការបន្តគាំទ្រពីអង្គភាពកិច្ចការសាធារណៈរបស់ អ.វ.ត.ក ។ នៅថ្ងៃច័ន្ទ អ្នកចូលស្តាប់សវនាការនៅសាលសាធារណៈមានជាង ៤៥០នាក់ មកពីបីឃុំ រួមមាន ឃុំរកាខ្ពស់ ឃុំសេដ្ឋបូ និងឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។ នៅថ្ងៃអង្គារ លោកគ្រូ-អ្នកគ្រូចំនួន ៤០០នាក់ មកពីក្រុងតាខ្មៅ និង ៤០នាក់ទៀត មកពីស្រុកអង្គស្នួល ខេត្តកណ្តាល ។ នៅថ្ងៃពុធ ប្រជាពលរដ្ឋចំនួន ៤៣០នាក់ មានវត្តមាននៅសាលសវនាការ មកពីស្រុកស្ទោង ខេត្តកំពង់ធំ និង ៥០នាក់ទៀត មកពីស្រុកបរិបូណ៌ ខេត្តកំពង់ចាម ។

***បញ្ហាកើតមានចំពោះកំណើនសាធារណៈជនចូលរួម :*** ការកើនឡើងកំរិតខ្ពស់នៃវត្តមានសាធារណៈជននៅសាលសវនាការនាពេលបច្ចុប្បន្ន នាំឱ្យកង្វះកៅអីអង្គុយដល់អ្នកចូលរួម ។ នៅថ្ងៃពុធ ប្រជាពលរដ្ឋជាច្រើនពុំទទួលបានកៅអីនៅសាលសវនាការ ដូច្នេះជំរុញឱ្យពួកគេតាមដានកិច្ចដំណើរការនីតិវិធីខាងក្រៅសាលសវនាការ តាមកញ្ចក់ទូរស្សន៍ផ្ទាយបន្តផ្ទាល់ ។ ការណ៍នេះចោទជាចម្ងល់ថាតើតម្លៃធ្វើដំណើរវែងឆ្ងាយគ្រាន់តែមកទស្សនាសវនាការតាមកញ្ចក់ទូរស្សន៍ ?

បន្ថែមលើកង្វះកន្លែងអង្គុយ អ្នកចូលរួមសវនាការត្រូវស៊ូទ្រាំនឹងភាពកកកុញនៅហាងកាហ្វេ និងបន្ទប់ទឹក ។ ក្រុមអ្នកឃ្លាំមើលតុលាការមានកង្វល់ថា បញ្ហាកើតមានបណ្តាលពីកង្វះការប្រាស្រ័យទាក់ទងរវាងអង្គភាពកិច្ចការសាធារណៈ និងអង្គការសង្គមស៊ីវិល ដែលអញ្ជើញប្រជាពលរដ្ឋពីសហគមន៍នានាចូលរួមសវនាការ ។ ភាពសហការណ៍រវាងតុលាការ និងសង្គមស៊ីវិលហាក់ត្រូវដោះស្រាយ និងពិភាក្សារកយុទ្ធសាស្ត្របន្ថែម ដើម្បីឱ្យកាន់តែឆាប់រហ័ស ។

***បញ្ហាបច្ចេកទេស*** **:** នៅថ្ងៃច័ន្ទ ការរំខានមួយដល់កិច្ចដំណើរនីតិវិធី ដោយសារការបកប្រែភាសាអង់គ្លេស និងបារាំងមិនអាចបញ្ជូនសម្លេងបាន ។

**តារាងពេលវេលា :**

| កាលបរិច្ឆេទ | ចាប់ផ្ដើម | សម្រាកពេលព្រឹក | សម្រាក អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការប្រចាំថ្ងៃ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ១០/០៨/០៩ | ០៩.០០ | ១០.៣៥ — ១០.៥៥ | ១២.០០ — ១.៣០ | ២.៥៥ — ៣.១៥ | ៤.១០ | ៥ម៉ោង ០០នាទី |
| ថ្ងៃអង្គារ ១១/០៨/០៩ | ០៩.០៥ | ១០.៤០ — ១១.០០ | ១២.១៥ — ១.៣០ | ២.៤០ — ៣.០០ | ៤.០០ | ៥ម៉ោង ០០នាទី |
| ថ្ងៃពុធ ១២/០៨/០៩ | ០៩.០០ | ១០.៣០ — ១០.៥០ | ១១.៤៥ — ១.៣០ | - | ២.៥០ | ៤ម៉ោង ៥០នាទី |

ចំនួនម៉ោងជាមធ្យម: ៤ម៉ោង ៥៧នាទី

ចំនួនម៉ោងសរុបប្រចាំសប្តាហ៍: ១៤ម៉ោង ៥០នាទី

ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍សរុបនៃសវនាការ: ២៥០ម៉ោង ៤នាទី ស្មើនឹងជាង៥៧ថ្ងៃសវនាការ និងជាង១៦សប្តាហ៍

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** (" កម្មវិធី ") : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ( អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សារិន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/ ។